NSW STATEWIDE INFANT SCREENING – HEARING (SWISH) PROGRAM

# Why does my baby need a repeat hearing screen?



## ហេតុអ្វីបានជាកូនខ្ញុំត្រូវការជាចាំបាច់នូវការពិនិត្យមើលសាឡើងវិញមួយចំពោះសោតវិញ្ញាណ?

ទារកជាច្រើនត្រូវការជាចាំបាច់នូវការពិនិត្យមើលសាឡើងវិញមួយចំពោះសោតវិញ្ញាណ។ ការពិនិត្យមើលសោតវិញ្ញាណសាឡើងវិញនេះ មិនមែនមានន័យថា កូនលោកអ្នកបាត់បង់សោតវិញ្ញាណ(ឬក៏ធ្ងន់ត្រចៀក)នោះទេ។ ការពិនិត្យមើលសោតវិញ្ញាណសាឡើងវិញនេះ អាចបណ្តាលមកពីមូលហេតុឯទៃផ្សេងទៀត។

បណ្តាមូលហេតុសាមញ្ញបំផុតសំរាប់ការពិនិត្យមើលសាឡើងវិញនៃសោតវិញ្ញាណនោះ គឺ:

- កូនលោកអ្នកអាចប្រហែលជាបានមានការភ័យភ្ញាក់ផ្អើល នៅគ្រាដែលគេឆែកពិនិត្យ។
- មានទឹកឬក៏អ្វីមួយរាំងស្ទះជាបណ្តោះអាសន្ននៅក្នុងត្រចៀកកូនលោកអ្នកក្រោយពីប្រសូតរួច។

នៅក្នុងករណីភាគច្រើន ការពិនិត្យមើលសាឡើងវិញនូវសោតវិញ្ញាណនេះ នឹងប្រព្រឹត្តទៅ មុនពេលដែលលោកអ្នកនិងកូនលោកអ្នកចេញពីមន្ទីរពេទ្យ។ បើសិនជាមិនអាចធ្វើទៅបាននៅគ្រាដែលលោកអ្នកបិតនៅក្នុងមន្ទីរពេទ្យទេនោះ គេនឹងស្នើផ្តល់ការពិនិត្យសោតវិញ្ញាណសាឡើងវិញចំពោះកូនលោកអ្នក ក្នុងលក្ខណៈជាអ្នកជម្ងឺមិនស្នាក់នៅក្នុងមន្ទីរពេទ្យ ឬក៏នៅតាមទីកន្លែងសហគមន៍មូលដ្ឋានណាមួយឲ្យបានឆាប់ ក្រោយពីលោកអ្នកចេញពីមន្ទីរពេទ្យរួច។

អ្នកដែលបានផ្តល់ខិត្តប័ណ្ណព័ត៌មាននេះទៅលោកអ្នក នឹងផ្តល់ឱវាទជូនលោកអ្នក អំពីពេលវេលានិងទីកន្លែងនៃការពិនិត្យមើលសោតវិញ្ញាណនេះសាឡើងវិញ។

ការពិភាក្សាជាមួយនឹងលោកអ្នកអំពីលទ្ធផលនៃការពិនិត្យមើលសោតវិញ្ញាណសាឡើងវិញ នឹងធ្វើឡើងនៅគ្រាដែលគេធ្វើការពិនិត្យនេះ។

បើសិនជាការពិនិត្យមើលសោតវិញ្ញាណសាឡើងវិញនេះ មិនបង្ហាញនូវលទ្ធផលច្បាស់លាស់ណាមួយនោះ គេនឹងបញ្ជូនកូនលោកអ្នកទៅជួបគ្រូពេទ្យសោតវិញ្ញាណម្នាក់ឲ្យធ្វើការវាយតម្លៃមួយ ដើម្បីវិនិច្ឆ័យសោតវិញ្ញាណនេះ។

ចំពោះព័ត៌មានបន្ថែម សូមទាក់ទង:

SWISH Information Line
Freecall 1800 551 175
NSW Department of Health
Tel. (02) 9391 9000
Fax. (02) 9391 9101
NSW HealthWeb site: www.health.nsw.gov.au

© NSW Health Department 2002

November 2002 SHPN (PHCC) 030087
Khmer

NSW HEALTH
Working as a Team